មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្ដីប្រកាសព័ត៌មាន

# មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាធ្វើយុទ្ធនាការប្រចាំឆ្នាំដើម្បីប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ

**រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១**

ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ គឺជាទិវាអន្តរជាតិដើម្បីបំបាត់អំពើហិង្សាទៅលើស្ត្រី។ អំពើហិង្សាទៅលើស្ត្រីគឺជាការរំលោភបំពានមួយនៃការរំលោភបំពានសិទ្ធិមនុស្ស ដែលកើតមានធ្ងន់ធ្ងរបំផុតក្នុងពិភពលោកនៅពេលបច្ចុប្បន្ន ហើយក៏ជាបញ្ហាប្រឈមសម្រាប់កម្ពុជាផងដែរ។ តាមការប៉ាន់ស្មាន មានស្ត្រីខ្មែរមួយនាក់ក្នុងចំណោមប្រាំនាក់ ទទួលរងអំពើហិង្សាពីដៃគូរបស់ពួកគេ ដែលចំនួននេះត្រូវបានគេជឿជាក់ថាបានកើនឡើងចាប់តាំងពីការរីករាលដាលនៃជំងឺកូវីដ-១៩។

ដើម្បីប្រារព្ធទិវានេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(ម.ស.ម.ក) ផ្តួចផ្តើមយុទ្ធនាការមួយដែលមានឈ្មោះថា «សកម្មភាព១៦ថ្ងៃ ដើម្បីបញ្ចប់អំពើហិង្សាផ្អែកទៅលើយេនឌ័រ» ដែលចាប់ផ្តើមពីថ្ងៃទី២៥ ខែវិច្ឆិកា រហូតដល់ទិវាសិទ្ធិមនុស្សថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ ។ ម.ស.ម.ក នឹងចូលរួមក្នុងយុទ្ធនាការនេះដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិស្ត្រី និងផលប៉ះពាល់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសហគមន៍ និងអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា(រដ្ឋាភិបាល) ចាត់វិធានការឲ្យបានច្បាស់លាស់និងទាន់ពេលវេលា ដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា។

នៅក្នុងអំឡុងពេលនេះ ម.ស.ម.ក ក៏នឹងចូលរួមក្នុងទិវាសំខាន់ៗមួយចំនួនផ្សេងទៀត នៅក្នុងប្រតិទិននៃទិវាសិទ្ធិមនុស្ស។ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ គឺជាទិវាអន្តរជាតិនៃអ្នកការពារសិទ្ធិមនុស្សជាស្ត្រី ហើយនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១ គឺជាទិវាអ្នកការពារសិទ្ធិមនុស្សអន្តរជាតិ ដែលជាថ្ងៃដ៏សំខាន់ដើម្បីប្រារព្ធទិវាអ្នកការពារសិទ្ធិមនុស្ស ដែលធ្វើការតស៊ូមតិ ការអប់រំ និងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្សនៅក្នុងសហគមន៍របស់ពួកគេ។ លើសពីនេះទៀត ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១ គឺជាទិវាសិទ្ធិមនុស្ស ដែលជាថ្ងៃដ៏សំខាន់ ដើម្បីប្រារព្ធខួបនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលជាឯកសារគោលនៃក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិ និងមានចែងពីសិទ្ធិជាមូលដ្ឋានសម្រាប់មនុស្សគ្រប់គ្នា។ ប្រធានបទនៃទិវាសិទ្ធិមនុស្សសម្រាប់ឆ្នាំ២០២១ គឺ «សមភាព ៖ កាត់បន្ថយវិសមភាព តាមរយៈការជំរុញការគោរពសិទ្ធិមនុស្ស» ដែលជាឱកាសសម្រាប់សង្គមស៊ីវិល ក៏ដូចជា ម.ស.ម.ក បន្តចូលរួមក្នុងការលុបបំបាត់វិសមភាពនៅក្នុងប្រទេសកម្ពុជា និងធ្វើការតស៊ូមតិដើម្បីសិទ្ធិស្មើគ្នាសម្រាប់ទាំងអស់គ្នា។

នៅក្នុងថ្ងៃសំខាន់ៗទាំងនេះ ជាឱកាសសម្រាប់ភាគីពាក់ព័ន្ធ ជាពិសេសអ្នកជាប់កាតព្វកិច្ចពោលគឺរដ្ឋាភិបាល និងតួអង្គសង្គមស៊ីវិល បង្ហាញការប្ដេជ្ញាចិត្តរបស់ពួកគេឡើងវិញក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។

ដើម្បីប្រារព្ធទិវាសំខាន់ៗទាំងនេះ ម.ស.ម.ក បានរៀបចំសកម្មភាពមួយចំនួនដូចខាងក្រោមនេះ ៖

- **ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១៖** នៅក្នុងទិវាអន្តរជាតិដើម្បីបំបាត់អំពើហិង្សាទៅលើស្ត្រី ម.ស.ម.ក នឹងចេញផ្សាយកាលប្បវត្តិការតស៊ូនិងការប្រឈមរបស់ស្ត្រីថ្ងៃសុក្រ។
- **ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០២១៖** ក្នុងឱកាសទិវាអ្នកការពារសិទ្ធិមនុស្សជាស្ត្រី ម.ស.ម.ក នឹងចេញផ្សាយវីដេអូមួយពាក់ព័ន្ធនឹងអ្នកការពារសិទ្ធិមនុស្សជាស្ត្រី។ នៅថ្ងៃដដែលនោះ ម.ស.ម.ក ក៏នឹងចេញផ្សាយសៀវភៅកម្រងជីវប្រវត្តិរបស់អ្នកការពារសិទ្ធិមនុស្សជាស្ត្រីនិងសកម្មជនអ្នកស្រលាញ់ភេទដូចគ្នាផងដែរ។
- **ថ្ងៃទី១ ខែធ្នូ ឆ្នាំ ២០២១៖** ម.ស.ម.ក នឹងបើកឱកាសដល់សាធារណជន ចូលរួមឆ្លើយសំណួរពាក់ព័ន្ធនឹងទិវាសិទ្ធិមនុស្សតាមរយៈទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក។
- **ថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០២១៖** ម.ស.ម.ក នឹងរៀបចំកម្មវិធីទិវាអ្នកការពារសិទ្ធិមនុស្សអន្តរជាតិ និងសិទ្ធិមនុស្ស១០ធ្នូ នៅការិយាល័យរបស់ម.ស.ម.ក និងមានផ្សាយបន្តផ្ទាល់តាមទំព័រហ្វេសប៊ុករបស់ ម.ស.ម.កផងដែរ។
- **ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២១៖** ម.ស.ម.ក នឹងចេញផ្សាយកាលប្បវត្តិសិទ្ធិមនុស្សឆ្នាំ២០២១ ដោយអមជាមួយវីដេអូបង្ហាញអំពីព្រឹត្តិការណ៍សំខាន់ៗ និងកម្រងខិត្តប័ណ្ណព័ត៌មានអំពីកាលប្បវត្តិសិទ្ធិមនុស្ស។ ជាកិច្ចបញ្ចប់នៃយុទ្ធនាការ ម.ស.ម.ក នឹងចេញផ្សាយប័ណ្ណព័ត៌មានពីអំពើហិង្សានិងជនរងគ្រោះដោយផ្អែកទៅលើយេនឌ័រ និងការទទួលបានយុត្តិធម៌ ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន យុធ្យា នាយកផ្នែកតស៊ូមតិ នៃ ម.ស.ម.ក តាម រយៈ អ៊ីម៉ែល** yuthyia@cchrcambodia.org **ឬទូរស័ព្ទ +៨៥៥ (0) ៨៨ ៨១ ៤២ ៧៨៣ និង លោក លឹម បូរិន អ្នកសម្របសម្រួលគម្រោងសំឡេងដើម្បីសមភាពយេនឌ័រតាមរយៈ** borin.lim@cchrcambodia.org **ឬទូរស័ព្ទ + ៨៥៥ (0) ១២ ៩០៤ ២៦៦៕**

<u>ចប់</u>

**បណ្ណាធិការៈ**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា«ម.ស.ម.ក» បានបង្កើតឡើងក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ គឺជាអង្គការមិនមែន រដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ពន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃ អង្គការផ្លាស់ប្តូរសេរីភាពបញ្ចេញមតិអន្តរជាតិ(IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពនៃការបញ្ចេញមតិ និង CIVICUS៖ សម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងទារុណកម្មពិភពលោក (OMCT SOS-Torture Network) និង ជាសមាជិក OECD Watch ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ" សិទ្ធិ និងសេរីភាព "និងបានទទួលពានរង្វាន់ ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រ៊ីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។